<u>ការរក្សារទុកជារឿងសម្ងាត់ នូវពត៌មានក្នុងពាក្យទទួលប្រាក់កម្រៃម្ហូបអាហារ</u>:

យើងខ្ញុំនិងប្រើប្រាស់ពត៌មានទៅក្នុងពាក្យនេះ ដើម្បីសម្រេចថាតើលោកអ្នក មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលប្រាក់កម្រៃកម្រិតទី១ (Tier I) ឬ ប្រសិនបើលោកអ្នកមានសិទ្ធដើម្បីសុំប្រាក់កម្រៃ សម្រាប់ម្ហូបអាហាររបស់កូនលោកអ្នកផ្ទាល់ ។ យើងប្រហែលអាច ប្រាប់មន្ត្រីឯទៀត នៃកម្មវិធី ដទៃទៀត ខាងជីវជាតិម្ហូបអាហារកូនក្មេង ខាងសុខភាព និងខាងវិស័យសិក្សាអប់រំ នូវពត៌មានទៅលើពាក្យសុំរបស់លោកអ្នក ដើម្បីសម្រេចអំពីផលកម្រៃសម្រាប់ កម្មវិធីទាំងនោះ ។

<u>មាត្រាប្រឆាំងជំទាស់និងការប្រកាន់រើសអើងនៃកម្មវិធី</u>:

ក្រសួងកសិកម្មសហរដ្ឋអាមេរិក(U.S. Department of Agriculture (USDA))

ហាមឃាត់មិនឱយមានការប្រកាន់រើសអើង នៅក្នុងកម្មវិធី និង សកម្មភាពរបស់ខ្លួនទាំងអស់ យោងទៅលើ ពូជសាសន៏ ដើមកំណើតជាតិ ភេទ អាយុ ឬ ភាពពិការ ។ ជនពិការណាដែល ត្រូវការវិធីទាក់ទងដទៃទៀត អំពីពត៌មាននៃកម្មវិធីនេះ (ឧទាហរណ៏ដូចជា អក្សរ BRAILLE សម្រាប់មនុស្សខ្វាក់ អក្សរពុម្ពធំ។ ឬ ខ្សែអាត់ថតសម្លេង ជាដើមនោះ) គួរទាក់ទងជាមួយមជ្ឈមណ្ឌល USDA's TARGET តាមរយះទូរសព្ទ័លេខ (202) 720-2600 (សម្លេង ឬ ប្រពន្ធ័ TDD) ។

ដើម្បីដាក់ពាក្យតវ៉ាប្រឆាំងនិងការប្រកាន់រើសអើង សូមសរសេរសំបុត្រទៅកាន់ USDA, Director, Office of Civil Rights, Room 326-W. Whitten Building, 14th and Independence Avenue, S.W., Washington, D.C. 20250-9410 ឬ ទូរសព្ទ័លេខ (202) 720-5964 (សម្លេង ឬ ប្រពន្ធ័ TDD)។

ក្រសួងកសិកម្មសហរដ្ឋអាមេរិក ជាអ្នកផ្តល់សេវា និង ជា និយោជក ផ្តល់ឱកាសស្មើ។គ្នា ដល់ជនរាល់រូប ។

សូមអគុណចំពោះកិច្ចសហប្រតិបត្តិការ របស់លោកអ្នក ។

ដោយការគោរពយ៉ាងស្មោះស្មគ្រ័

ហត្ថលេខារបស់អ្នកតំណាងនៃអង្គការធានាគាំទ្រ ថ្ងៃខែនិងឆ្នាំ

Cambodian